**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦/៩៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១. – គោលបំណង

អនុក្រឹត្យនេះមានគោលបំណងកំណត់ នីតិវិធីនៃការចុះបញ្ជីម៉ាក ការបដិសេធ ភ្នាក់ងារតំណាង ការប្រកាសសិទ្ធិជាអាទិភាព ការលុបម៉ាកចេញពីបញ្ជី និងវិធានការតាមមាត់ច្រកព្រំដែន សំដៅអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ នៃព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២. – និយមន័យ

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចក្នុងឧបសម្ព័ន្ធភ្ជាប់ ។

## ជំពូកទី ២

## លក្ខខណ្ឌទូទៅ នៃការស្នើសុំចុះបញ្ជីម៉ាក

### មាត្រា ៣. – គំរូពាក្យស្នើសុំ

គំរូពាក្យស្នើសុំ ដែលបោះពុម្ពរួចត្រូវចែកជូន ដល់អ្នកដាក់ពាក្យស្នើសុំដោយឥតគិតថ្លៃ ដោយមន្ត្រីកាន់កាប់បញ្ជី ។

គំរូពាក្យស្នើសុំ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

### មាត្រា ៤. – ភាសាប្រើប្រាស់ក្នុងឯកសារដាក់ពាក្យស្នើសុំ និងការបកប្រែ

តាមការតម្រូវនៃច្បាប់ ឬអនុក្រឹត្យនេះ ពាក្យស្នើសុំត្រូវធ្វើជាភាសាខ្មែរ ឬជាភាសាអង់គ្លេស ។ ឯកសារណាមួយ ដែលប្រើប្រាស់អមភ្ជាប់ជាមួយពាក្យស្នើសុំ ដែលបង្កើតជាផ្នែកមួយ នៃពាក្យស្នើសុំនោះ ឬ ឯកសារដែលបានដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ដែលប្រើប្រាស់ភាសាណាមួយ ក្រៅពីភាសាខ្មែរ ឬ ភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយ នូវការបកប្រែជាភាសាខ្មែរ ឬ ភាសាអង់គ្លេស ។

### មាត្រា ៥. – ការបញ្ជាក់ឈ្មោះ អាសយដ្ឋាន សញ្ជាតិ និង និវេសនដ្ឋាន របស់អ្នកដាក់ពាក្យស្នើសុំ

១-ឈ្មោះរបស់រូបវន្តបុគ្គល ត្រូវបញ្ជាក់ដោយនាមត្រកូល និងនាមខ្លួនរបស់បុគ្គលនោះ ឈ្មោះនីតិបុគ្គល ត្រូវបញ្ជាក់ដោយឈ្មោះពេញលេញ ជាផ្លូវការរបស់នីតិបុគ្គលនោះ ។

២-អាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ដើម្បីបំពេញតម្រូវការជាធម្មតាសម្រាប់សម្រួលដល់ការបញ្ជូនតាមប្រៃសណីយ៍ ។ ក្នុងករណីណាក៏ដោយ អាសយដ្ឋាន ត្រូវមានការបញ្ជាក់ផងដែរ នូវលេខផ្ទះ ទូរស័ព្ទ និង ទូរសារ ។

៣-សញ្ជាតិត្រូវបញ្ជាក់នូវឈ្មោះរដ្ឋ ឬប្រទេស ដែលបុគ្គលនោះជាពលរដ្ឋនៃរដ្ឋ ឬប្រទេសនោះ។ ចំពោះនីតិបុគ្គលត្រូវបញ្ជាក់ឈ្មោះរដ្ឋ ឬប្រទេស ដែលនីតិបុគ្គលនោះ ត្រូវបានបង្កើតឡើង តាមច្បាប់របស់រដ្ឋ ឬប្រទេសនោះ ព្រមទាំងការិយាល័យ របស់នីតិបុគ្គលនោះដែលបានចុះបញ្ជីរួច។

៤-និវេសនដ្ឋាន ត្រូវបញ្ជាក់នូវឈ្មោះរដ្ឋ ឬប្រទេស ដែលបុគ្គលនោះមានទីលំនៅជាអចិន្ត្រៃយ៍។

## មាត្រា ៦. – ហត្ថលេខាក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនមូលធន និង សមាគម

១-ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមួយ ត្រូវមានឈ្មោះរបស់ម្ចាស់ភាគហ៊ុនទាំងអស់ ជាឈ្មោះពេញលេញ និងត្រូវចុះហត្ថលេខា ដោយម្ចាស់ភាគហ៊ុនទាំងអស់ ឬដោយម្ចាស់ភាគហ៊ុនណាមួយ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីចុះហត្ថលេខា ដោយមានបញ្ជាក់ថា ម្ចាស់ភាគហ៊ុននោះចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬដោយតតិយជនណាម្នាក់ដែលមន្ត្រី កាន់កាប់បញ្ជីទទួលស្គាល់ថា ជននោះត្រូវអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារនោះ។ ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនមូលធន ជូសមុខឱ្យនីតិបុគ្គលមួយ ត្រូវចុះហត្ថលេខាដោយអភិបាលមួយរូប ឬដោយលេខាធិការ ឬមន្ត្រីសំខាន់ដទៃទៀត របស់នីតិបុគ្គលនោះ ឬចុះហត្ថលេខាដោយតតិយជនណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា ជននោះត្រូវអនុញ្ញាតឱ្យធ្វើការចុះហត្ថលេខាលើឯកសារនោះ ហើយឯកសារនោះត្រូវមានប្រថាប់ត្រា របស់នីតិបុគ្គលនោះផង។ ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមសមាគមមួយ ត្រូវចុះហត្ថលេខាដោយបុគ្គលណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះបានទទួលសិទ្ធិស្របច្បាប់ ដើម្បីចុះហត្ថលេខា ហើយត្រូវប្រថាប់ត្រារបស់សមាគមនោះផង។

២-នៅពេលចាំបាច់ មន្ត្រីកាន់កាប់បញ្ជី អាចស្នើសុំឱ្យផ្តល់ភស្តុតាងនៃការប្រគល់សិទ្ធិ ក្នុងការចុះហត្ថលេខានោះ ។

## មាត្រា ៧. – ភ្នាក់ងារតំណាង

លិខិតប្រគល់សិទ្ធិ ដែលចាត់តាំងភ្នាក់ងារតំណាងមួយឱ្យធ្វើការដាក់ពាក្យ អាចភ្ជាប់ជាមួយនឹងពាក្យស្នើសុំចុះបញ្ជី ឬ ត្រូវប្រគល់លិខិតប្រគល់សិទ្ធិនោះ ទៅឱ្យមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេល ០២ (ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យ។ ប្រសិនបើការប្រគល់សិទ្ធិនេះ មិនត្រូវបានធ្វើឡើង

និង ធ្វើឡើងមិនសមស្របតាមមាត្រា៥៨ និង មាត្រា៥៩ នៃច្បាប់ និង មាត្រា២៨ នៃអនុក្រឹត្យនេះទេនោះ ចំណាត់ការតាមនីតិវិធីណាមួយ ក្នុងការចុះបញ្ជី នឹងមិនត្រូវធ្វើឡើងឡើយ ។

### មាត្រា ៨. – កម្រៃផ្សេងៗ

កម្រៃផ្សេងៗ ដែលតម្រូវតាមច្បាប់ ឬតាមអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ៣
## នីតិវិធីនៃការចុះបញ្ជីម៉ាក
## ការបដិសេធការចុះបញ្ជីម៉ាក និងការលុបម៉ាកចេញពីបញ្ជី

## ផ្នែកទី ១

## ពាក្យស្នើសុំចុះបញ្ជីម៉ាក នីតិវិធីនៃការចុះបញ្ជីម៉ាក និងការបោះពុម្ពផ្សាយ

### មាត្រា ៩. – ចំណាត់ថ្នាក់នៃម៉ាក

ក្នុងការចុះបញ្ជី និងការបោះពុម្ពផ្សាយម៉ាក មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាម "ចំណាត់ថ្នាក់អន្តរជាតិ នៃទំនិញ និង សេវា នៃការចុះបញ្ជីម៉ាក" ដែលអនុម័តដោយកិច្ចព្រមព្រៀងទីក្រុង នីស ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៥៧ ហើយដែលចំណាត់ថ្នាក់នេះ បានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

### មាត្រា ១០. – ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមួយ ត្រូវធ្វើឡើងតាមរយៈគំរូពាក្យស្នើសុំ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ហើយត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់ ។ ពាក្យស្នើសុំមួយ អាចធ្វើឡើងសម្រាប់ការស្នើសុំចុះបញ្ជីម៉ាកមួយ ចំពោះទំនិញ ឬសេវាក្នុងចំណាត់ថ្នាក់មួយ ឬច្រើននៃចំណាត់ថ្នាក់អន្តរជាតិ ។

ការប្រើប្រាស់ម៉ាកពុំមែនជាលក្ខខណ្ឌដែលតម្រូវ នៅពេលដាក់ពាក្យស្នើសុំ ចុះបញ្ជីម៉ាកឡើយ ។

### មាត្រា ១១. – ការផ្តល់គំរូម៉ាក

១-ពាក្យស្នើសុំចុះបញ្ជី ត្រូវភ្ជាប់មកជាមួយនូវគំរូម៉ាក ក្រោមរូបភាពជាគំនូសក្រាផិចច្បាស់ និងមិនរលុប ដែលមានទំហំមិនលើសពី ៨សង់ទីម៉ែត្រ គុណ ៨សង់ទីម៉ែត្រ បិទភ្ជាប់ក្នុងចន្លោះកន្លែង

ដែលបានផ្តល់ជូន នៅលើគំរូពាក្យស្នើសុំចុះបញ្ជីម៉ាក ។ គ្រប់ករណីទាំងអស់ គំរូម៉ាកត្រូវពិពណ៌នាគ្រប់ចំណុចលំអិតទាំងអស់ ដែលចំណុចលំអិតទាំងនោះ អាចនឹងត្រូវទាមទារក្នុងពេលណាមួយដែលចាំបាច់ដោយមន្ត្រីកាន់កាប់បញ្ជី ។ ប្រសិនបើ មានលក្ខខណ្ឌតម្រូវ ចំណុចលំអិតទាំងនោះ ត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំ ឬដោយភ្នាក់ងារតំណាង ដែលបានទទួលសិទ្ធិ។

២-គំរូម៉ាកបន្ថែមចំនួន ១៥ (ដប់ប្រាំ) ទៀត ត្រូវភ្ជាប់ជាមួយនឹងគ្រប់ពាក្យស្នើសុំចុះបញ្ជីម៉ាក។ គំរូម៉ាក ដែលបិទភ្ជាប់នៅលើពាក្យស្នើសុំ និងគំរូម៉ាកបន្ថែម ត្រូវមានលក្ខណៈដូចគ្នាបេះបិទ ។

៣-ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ថា គំរូម៉ាកណាមួយនៅមិនទាន់សមស្របសម្រាប់ការចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជី អាចទាមទារឱ្យផ្តល់គំរូម៉ាកមួយទៀត ដែលសមស្រប ដើម្បីជំនួសគំរូចាស់។

៤-នៅពេលដែលគំរូ ឬការចម្លងឡើងវិញផ្សេងទៀត ពុំបានធ្វើឡើងតាមលក្ខណៈ ដូចបានពោលខាងលើនោះ គំរូម៉ាក ឬរូបភាពចម្លងនៃម៉ាក អាចនឹងត្រូវផ្តល់ក្រោមរូបភាព ជាទំហំពេញលេញ ឬ បំព្រួញ និងតាមទម្រង់មួយ ដែលមន្ត្រីកាន់កាប់បញ្ជីយល់ថាសមស្រប។

## មាត្រា ១២. – សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាក

តាមការតម្រូវរបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងករណីដែលម៉ាកមួយ មានពាក្យមួយព្យាង្គ ឬច្រើនព្យាង្គ ជាអក្សរ ក្រៅពីអក្សរខ្មែរ ឬអក្សររ៉ូម៉ាំង ការបំពេញពាក្យស្នើសុំតាមគំរូ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ហើយនិងការផ្តល់នូវគំរូម៉ាកបន្ថែម ត្រូវភ្ជាប់មកជាមួយផងដែរ នូវការសរសេរ សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាកនោះ ឱ្យបានពេញលេញតាមពាក្យមួយព្យាង្គៗ ដោយបញ្ជាក់នូវភាសា ដែលពាក្យនីមួយៗនោះ ត្រូវបានប្រើប្រាស់ ។

## មាត្រា ១៣. – ការប្រកាសសិទ្ធិអាទិភាព និងការបកប្រែពាក្យស្នើសុំលើកដំបូង

១-អនុលោមតាមមាត្រា៦ នៃច្បាប់ ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចអមមកជាមួយសេចក្តីប្រកាសទាមទារសិទ្ធិអាទិភាព នៃការដាក់ពាក្យស្នើសុំលើកដំបូង នៅក្រៅប្រទេស ក្នុងកម្រិតជាតិ ឬកម្រិតតំបន់ ដែលបានធ្វើឡើងដោយអ្នកដាក់ពាក្យស្នើសុំ ឬអ្នកទទួលសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញាទីក្រុង ប៉ារីស ដែលផ្តល់សិទ្ធិអាទិភាពនៅក្នុងរដ្ឋណាមួយ ជាសមាជិករបស់អនុសញ្ញានោះ។ ក្នុងករណីនេះមន្ត្រីកាន់កាប់បញ្ជី អាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ នូវច្បាប់ចម្លង នៃពាក្យស្នើសុំចុះបញ្ជីលើកដំបូងមួយច្បាប់ ដែលបានបញ្ជាក់ថា ត្រឹមត្រូវពីការិយាល័យទទួលពាក្យស្នើសុំចុះបញ្ជីនោះ ក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខណ្ឌ (៣) នៃមាត្រានេះ ។ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬអ្នកទទួលសិទ្ធិរបស់គាត់ អាចធ្វើការទាមទារសិទ្ធិអាទិភាព ពីការចុះបញ្ជីលើកដំបូង ដែលបានធ្វើឡើង នៅក្នុងរដ្ឋ ឬប្រទេសណាមួយ ជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកផងដែរ ។

២-ការប្រកាសអំពីសិទ្ធិអាទិភាព ដែលធ្វើឡើងតាមមាត្រា៦ នៃច្បាប់ និង មាត្រា១៣ កថាខ័ណ្ឌ (១) នៃអនុក្រឹត្យនេះ ត្រូវបញ្ជាក់នូវ ៖

ក- កាលបរិច្ឆេទដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង

ខ- លេខដាក់ពាក្យនៃការស្នើសុំចុះបញ្ជីម៉ាកលើកដំបូង អនុលោមតាមកថាខ័ណ្ឌ (៣) ខាងក្រោមនៃមាត្រានេះ

គ- ឈ្មោះប្រទេស ដែលអ្នកស្នើសុំចុះបញ្ជីម៉ាក បានដាក់ពាក្យលើកដំបូង ឬ ក្នុងករណីដែលពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ទៅជាការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្រោមរូបភាពតំបន់ ឬ អន្តរជាតិ។ អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់ឈ្មោះការិយាល័យ និង ឈ្មោះប្រទេស ដែលពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ ត្រូវដាក់ ។

៣-ប្រសិនបើនៅពេលដាក់សេចក្តីប្រកាស ដែលបានចែងក្នុងកថាខ័ណ្ឌ (១) និង (២) ខាងលើ ហើយអ្នកដាក់ពាក្យពុំទាន់ដឹងលេខដាក់ពាក្យ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូងទេ អ្នកដាក់ពាក្យស្នើសុំ ត្រូវផ្តល់លេខដាក់ពាក្យនោះ ក្នុងរយៈពេល ០៣ (បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលបានប្រកាសសុំសិទ្ធិអាទិភាពនោះ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំផ្តល់ នូវភស្តុតាងគ្រប់គ្រាន់ ដែលបង្ហាញថា ការដែលគាត់ពុំអាចអនុវត្តបានត្រឹមត្រូវ តាមកាលកំណត់ខាងលើ ដោយសារមានកាលៈទេសៈជាឧបសគ្គមួយចំនួន ហួសពីសមត្ថភាពគ្រប់គ្រងរបស់គាត់ មន្ត្រីកាន់កាប់បញ្ជីអាចពន្យារពេល ០៣ (បី) ខែទៀតចំពោះកាលកំណត់ នៃការផ្តល់នូវលេខដាក់ពាក្យ ដែលមានចែងក្នុងកថាខ័ណ្ឌនេះ ។

៤-ក្នុងករណីមានការស្នើសុំសិទ្ធិអាទិភាព នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ចំនួន ០២ (ពីរ) ឬ ច្រើនជាង ដែលអនុលោមតាមកថាខ័ណ្ឌ (១) ខាងលើ ការបញ្ជាក់អំពីការដាក់ពាក្យស្នើសុំសិទ្ធិអាទិភាព អាចបញ្ចូល ក្នុងប្រកាសទាមទារសិទ្ធិអាទិភាព តែមួយបាន ។

៥-ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីរកឃើញថា លក្ខខណ្ឌតម្រូវទាំងឡាយតាមមាត្រា៦ នៃច្បាប់ និង កថាខ័ណ្ឌ (១) (២) និង (៣) ខាងលើ មិនត្រូវបំពេញគ្រប់គ្រាន់ទេនោះ ការប្រកាសទាមទារសិទ្ធិអាទិភាព នឹងមិនត្រូវចាត់ទុកថា បានធ្វើឡើងឡើយ ។

៦-មុនពេលធ្វើការចុះបញ្ជីម៉ាក អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចធ្វើការកែតម្រូវការប្រកាសទាមទារ សិទ្ធិអាទិភាពរបស់ខ្លួន ដែលធ្វើឡើងតាមកថាខ័ណ្ឌនានាខាងលើបាន ។

**មាត្រា ១៤. – ច្បាប់ចម្លងនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង**

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវបានអនុញ្ញាតរយៈពេល ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទាមទាររបស់មន្ត្រីកាន់កាប់បញ្ជី ដើម្បីផ្តល់នូវច្បាប់ចម្លង នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ដោយមានការបញ្ជាក់នូវភាពត្រឹមត្រូវ ។

**មាត្រា ១៥. – ការដកពាក្យស្នើសុំចុះបញ្ជីម៉ាក**

ការដកពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់ ហើយត្រូវដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ។

កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នឹងមិនត្រូវផ្តល់ជូនវិញទេ ក្នុងករណីដែលមានការដកពាក្យស្នើសុំចុះបញ្ជីម៉ាក ទៅវិញនោះ ។

**មាត្រា ១៦. – ការកត់ត្រាពាក្យស្នើសុំចុះបញ្ជីម៉ាក និងកាលបរិច្ឆេទដាក់ពាក្យស្នើសុំ**

១-មន្ត្រីកាន់កាប់បញ្ជី ត្រូវកត់ត្រានៅលើសំណុំឯកសារ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកនីមួយៗនូវកាលបរិច្ឆេទពិតប្រាកដ និង លេខរៀងដាក់ពាក្យនៃពាក្យស្នើសុំចុះបញ្ជី ដោយមានសរសេរអក្សរ KH ភ្ជាប់នឹងរបាផ្តេក ហើយសរសេរលេខចំនួន ០៥ (ប្រាំ) ខ្ទង់យ៉ាងតិច ដែលកំណត់តាមលំដាប់លំដោយបន្តបន្ទាប់ ព្រមទាំងលេខចុងក្រោយពីរខ្ទង់នៃឆ្នាំ ដែលទទួលបានសំណុំឯកសារ ពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ។ នៅពេលដែលមានការកែតម្រូវណាមួយ ឬនៅពេលដែលទទួលបានឯកសារដទៃទៀត ដែលដាក់ជូនក្នុងកាលបរិច្ឆេទខុសគ្នានោះ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាកាលបរិច្ឆេទជាក់ស្តែង នៃការទទួលឯកសារទាំងនោះ។

២-លេខដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលបានកំណត់នៅក្នុងកថាខណ្ឌ (១) ខាងលើ ត្រូវយកមកប្រើក្នុងគ្រប់ទំនាក់ទំនង ជាបន្តបន្ទាប់ ដែលពាក់ព័ន្ធនឹងការស្នើសុំចុះបញ្ជីម៉ាក ។

៣-មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់នូវកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នៅពេលពាក្យស្នើសុំចុះបញ្ជី បំពេញបាននូវព័ត៌មានគ្រប់គ្រាន់ និងត្រឹមត្រូវដូចខាងក្រោម៖

- ក- ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក
- ខ- អាសយដ្ឋានទំនាក់ទំនង
- គ- គំរូម៉ាក ដែលស្នើសុំចុះបញ្ជី
- ឃ- យថាប្រភេទរបស់ទំនិញ ឬសេវា ដែលស្នើសុំចុះបញ្ជីក្នុងចំណាត់ថ្នាក់នីមួយៗ
- ង- កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលតម្រូវសម្រាប់ចំណាត់ថ្នាក់នីមួយៗ នៃទំនិញ ឬសេវា ដែលស្នើសុំចុះបញ្ជីម៉ាក ។

៤-មន្ត្រីកាន់កាប់បញ្ជី ត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យ ជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នូវលេខរៀង និងកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំ ។

**មាត្រា ១៧. – ការច្រានចោលការដាក់ពាក្យស្នើសុំចុះបញ្ជី ឬការយល់ព្រមទទួលដោយមានលក្ខខណ្ឌចំពោះការចុះបញ្ជី និងសវនាការ**

១-នៅពេលពិនិត្យសំណុំឯកសារ ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលធ្វើឡើងតាមមាត្រា៨ (ក) នៃច្បាប់ ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីសម្រេចច្រានចោល ពាក្យស្នើសុំចុះបញ្ជីម៉ាកណាមួយ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការច្រានចោលនោះ ទៅអ្នកដាក់ពាក្យស្នើសុំដោយភ្ជាប់នូវព័ត៌មានលំអិតទាំងអស់ ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន ហើយស្នើឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើការកែតម្រូវពាក្យស្នើសុំចុះបញ្ជីរបស់ខ្លួន និងធ្វើចម្លើយតបទៅមន្ត្រីកាន់កាប់បញ្ជី ជាលាយលក្ខណ៍អក្សរ ឬធ្វើការដាក់ពាក្យស្នើសុំធ្វើសវនាការ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីពេលទទួលបានសេចក្តីជូនដំណឹងអំពី ការច្រានចោលនោះ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមិនបានអនុវត្តទៅតាមកាលកំណត់ នៃការជូនដំណឹងនេះទេ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ នឹងត្រូវចាត់ទុកថា បានដកពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន ។

២-នៅពេលពិនិត្យខ្លឹមសារម៉ាក ដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី ដោយធ្វើឡើងតាមមាត្រា៨ (ខ) នៃច្បាប់ ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ព្រមទទួលយកពាក្យស្នើសុំ ក្នុងលក្ខខណ្ឌនៃការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ លើចំណុចណាមួយរបស់ម៉ាក ឬការកម្រិតកំណត់សិទ្ធិ ឬ លក្ខខណ្ឌផ្សេងៗទៀត មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងអំពីការសម្រេចរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ទៅឱ្យអ្នកដាក់ពាក្យស្នើសុំ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មិនឯកភាពចំពោះការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ ឬការកម្រិតកំណត់នៃសិទ្ធិ ឬ លក្ខខណ្ឌផ្សេងៗទៀត អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចដាក់ពាក្យស្នើសុំធ្វើសវនាការ ឬផ្តល់នូវការយល់ឃើញរបស់ខ្លួន ជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីជូនដំណឹងពីមន្ត្រីកាន់កាប់បញ្ជី។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកឯកភាព ទៅនឹងសំណូមពរឱ្យធ្វើការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ ឬការកម្រិតកំណត់ នៃសិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីវិញ ជាលាយលក្ខណ៍អក្សរ ហើយធ្វើការកែតម្រូវពាក្យស្នើសុំរបស់ខ្លួន ទៅតាមសេចក្តីជូនដំណឹងខាងលើ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក មិនធ្វើការឆ្លើយតបតាមកាលកំណត់ និងតាមវិធីណាមួយក្នុងចំណោមវិធីខាងលើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវចាត់ទុកថា បានបោះបង់ចោលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន។

៣-ការស្នើសុំធ្វើសវនាការមួយ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយផ្ញើជូនទៅមន្ត្រីកាន់កាប់បញ្ជី។ នៅពេលដែលទទួលបានពាក្យស្នើសុំនេះ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកយ៉ាងយូរ ០១ (មួយ)ខែ មុនកាលបរិច្ឆេទ ដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវអញ្ជើញមកចូលរួមក្នុងសវនាការ ។

## មាត្រា ១៨.- ការបដិសេធពាក្យស្នើសុំចុះបញ្ជី ឬ ការយល់ព្រម ដោយមានលក្ខខណ្ឌរបស់មន្ត្រីកាន់កាប់បញ្ជី ដែលអ្នកដាក់ពាក្យស្នើសុំធ្វើការជំទាស់

១-បន្ទាប់ពីសវនាការ ឬបន្ទាប់ពីការពិនិត្យពិចារណា លើការស្នើសុំកែតម្រូវ ឬការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ពីអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធការចុះបញ្ជី ឬយល់ព្រមចុះបញ្ជី ដោយមានលក្ខខណ្ឌឱ្យមានការកែតម្រូវ ការកែសម្រួល ការឈប់ទាមទារសិទ្ធិ ឬការកម្រិតកំណត់សិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត ហើយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី នៅតែមិនយល់ព្រមទៅនឹងការច្រានចោល ឬការយល់ព្រមទទួលចុះបញ្ជីជូនដោយមានលក្ខខណ្ឌ មន្ត្រីកាន់កាប់បញ្ជី ត្រូវបដិសេធជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំ អំពីសេចក្តីសម្រេចរបស់ខ្លួន ។ ក្នុងរយៈពេល ០១ (មួយ) ខែ ចាប់ពីកាលបរិច្ឆេទនៃការផ្តល់សេចក្តីជូនដំណឹងនេះ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី អាចស្នើសុំឱ្យមន្ត្រីកាន់កាប់បញ្ជី ធ្វើការបញ្ជាក់ជាលាយលក្ខណ៍អក្សរ អំពីមូលហេតុដែលនាំឱ្យឈានដល់សេចក្តីសម្រេចរបស់ខ្លួន ព្រមទាំងឯកសារយោងទាំងឡាយ ដែលប្រើប្រាស់នៅក្នុងការធ្វើសេចក្តីសម្រេចនេះ ។

២-អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងតវ៉ា អំពីការបដិសេធមិនព្រមចុះបញ្ជី របស់មន្ត្រីកាន់កាប់បញ្ជី ទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៃក្រសួងពាណិជ្ជកម្ម ឬទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច របស់មន្ត្រីកាន់កាប់បញ្ជី ។

៣-អនុលោមតាមមាត្រា៦២ នៃច្បាប់ ភាគីមានផលប្រយោជន៍ មានសិទ្ធិប្តឹងតវ៉ា អំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៃក្រសួងពាណិជ្ជកម្មទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី ) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច របស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា។

## មាត្រា ១៩.- ការយល់ព្រមចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជី ការចុះបញ្ជីម៉ាក ការបោះពុម្ពផ្សាយ និង ការចេញវិញ្ញាបនបត្រ

១-ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ព្រម ចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដោយមាន ឬ គ្មានលក្ខខណ្ឌ ឬការកម្រិតកំណត់ណាមួយ ដែលលក្ខខណ្ឌ និងការកំណត់ទាំងនោះ ត្រូវបានយល់ព្រមដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក និងចេញវិញ្ញាបនបត្រ នៃការ

ចុះបញ្ជីម៉ាកជូនអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ហើយត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកនោះ នៅក្នុងព្រឹត្តិបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

២-មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់នូវលេខរៀងមួយតាមលំដាប់លំដោយ នៃការចុះបញ្ជីម៉ាកនៅលើវិញ្ញាបនបត្រចុះបញ្ជី ។

៣-ការចុះបញ្ជីម៉ាកមួយត្រូវមាន ៖

ក- គំរូម៉ាក ដែលត្រូវបានចុះបញ្ជី

ខ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

គ- ឈ្មោះ និង អាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលស្នើសុំចុះបញ្ជី

ឃ- ឈ្មោះ និង អាសយដ្ឋានរបស់ភ្នាក់ងារតំណាង ( ប្រសិនបើមាន)

ង- កាលបរិច្ឆេទនៃការដាក់ពាក្យ និងកាលបរិច្ឆេទនៃការចុះបញ្ជី

ច- ប្រសិនបើសិទ្ធិអាទិភាពត្រូវបានទាមទារ ហើយការទាមទារសិទ្ធិនោះត្រូវបានយល់ព្រម ត្រូវបញ្ជាក់ឈ្មោះ រដ្ឋ ឬប្រទេស និងលេខដាក់ពាក្យដែលបានដាក់ពាក្យស្នើសុំលើកដំបូង ។

ឆ- ចំណាត់ថ្នាក់ និង ទំនិញ ឬសេវាដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានបញ្ជាក់អំពីចំណាត់ថ្នាក់នៃទំនិញ ឬសេវានោះ ស្របតាមចំណាត់ថ្នាក់អន្តរជាតិ ។

៤-ការបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកមួយ ដែលបានកំណត់ក្នុងកថាខណ្ឌ (១) ខាងលើត្រូវមានព័ត៌មានមួយចំនួនដូចតទៅ ៖

ក- កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និង កាលបរិច្ឆេទនៃសិទ្ធិអាទិភាព ( ប្រសិន បើមាន)

ខ- គំរូម៉ាក ដែលបានចុះបញ្ជី

គ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

ឃ- ចំណាត់ថ្នាក់ និង ទំនិញ ឬ សេវា ដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានបញ្ជាក់អំពីចំណាត់ថ្នាក់នៃទំនិញ ឬសេវានោះ ស្របតាមចំណាត់ថ្នាក់អន្តរជាតិ

ង- ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលបានចុះបញ្ជី

ច- ឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារតំណាង ( ប្រសិនបើមាន) ។

## មាត្រា ២០. – បណ្ដឹងជំទាស់

១-ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតចាប់តាំងពីកាលបរិច្ឆេទ នៃការបោះពុម្ពផ្សាយ ដូចមាន ចែងក្នុងមាត្រា១៩នៃអនុក្រឹត្យនេះរាល់លិខិតជំទាស់របស់ជនណា ដែលមានការពាក់ព័ន្ធនឹងការ ចុះបញ្ជីម៉ាក តាមមាត្រា១០ (គ) នៃច្បាប់ ត្រូវធ្វើឡើងតាមគំរូដែលកំណត់ ដោយក្រសួងពាណិជ្ជកម្ម ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារគាំទ្រនានាជាភស្តុតាងផង ។

២-អនុលោមតាមមាត្រា១០ (ង) នៃច្បាប់ ក្នុងរយៈពេល ៩០ (កៅសិប ) ថ្ងៃ គិតពីកាល បរិច្ឆេទ នៃការជូនដំណឹងពីបណ្ដឹងជំទាស់ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវផ្ដល់អំណះអំណាងជាចម្លើយ តបវិញ ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីហេតុផលជាមូលដ្ឋាន ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក របស់ខ្លួន និងមានភ្ជាប់មកជាមួយនូវឯកសារគាំទ្រនានាជាភស្តុតាងផង ។

## មាត្រា ២១. – សេចក្ដីប្រកាសអំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក និង ភស្តុតាង

១-ដើម្បីរក្សាសុពលភាពនៃការចុះបញ្ជីម៉ាក ឬការចុះបញ្ជីម៉ាកសាឡើងវិញ ម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ត្រូវប្រកាសអំពីការប្រើប្រាស់ម៉ាក ឬមិនបានប្រើប្រាស់ម៉ាកក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីខួបលើកទី ៥ (ប្រាំ) នៃកាលបរិច្ឆេទចុះបញ្ជីម៉ាក ។

២-នៅពេលម៉ាក ត្រូវបានចុះបញ្ជីសាឡើងវិញ ម្ចាស់ម៉ាកត្រូវប្រកាសអំពីការប្រើប្រាស់ម៉ាក ឬ មិនបានប្រើប្រាស់ម៉ាករបស់ខ្លួន ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីខួបលើកទី ០៥ (ប្រាំ) នៃកាលបរិច្ឆេទចុះបញ្ជីសាឡើងវិញ ។

៣-សេចក្ដីប្រកាសអំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវធ្វើឡើងតាមគំរូដែលបាន កំណត់ ដោយក្រសួងពាណិជ្ជកម្ម និងត្រូវបង់កម្រៃតាមប្រកាសអន្តរក្រសួង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ។

៤-ម៉ាកដែលបានចុះបញ្ជីរួច នឹងត្រូវលុបចេញពីបញ្ជីវិញ ក្នុងករណីដែលម្ចាស់ម៉ាក ឬភ្នាក់ងារ តំណាងខកខានមិនបានប្រកាស អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកនោះ ដូចដែលបានកំណត់ក្នុង កថាខណ្ឌ (១) ខាងលើ ។

## មាត្រា ២២. – ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ

១-ពាក្យស្នើសុំចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ តាមមាត្រា១២ (ខ) នៃច្បាប់ អាចធ្វើឡើង ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ មុនពេលផុតសុពលភាព នៃការចុះបញ្ជីម៉ាក ហើយពាក្យស្នើសុំចុះបញ្ជី សាជាថ្មីឡើងវិញនេះ ត្រូវចុះហត្ថលេខាដោយម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ឬដោយភ្នាក់ងារតំណាង របស់ខ្លួន ។

២-ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ អាចធ្វើឡើងបាន ដោយមានការទូទាត់កម្រៃនៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ដែលត្រូវធ្វើនៅក្នុងរយៈពេលកំណត់ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ (១) ខាងលើ ឬ ធ្វើឡើងក្នុងរយៈពេលនៃការអនុគ្រោះ ដែលអនុញ្ញាតដោយមាត្រា១២ (ឃ) នៃច្បាប់ ។

៣-ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ត្រូវតែកត់ត្រានៅក្នុងបញ្ជីម៉ាក ហើយត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

៤-មន្ត្រីកាន់កាប់បញ្ជីត្រូវចេញវិញ្ញាបនបត្រ នៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ទៅឱ្យម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ហើយវិញ្ញាបនបត្រនោះត្រូវមានព័ត៌មានដូចខាងក្រោម :

ក- លេខចុះបញ្ជីដើមរបស់ម៉ាក

ខ- គំរូម៉ាក

គ- កាលបរិច្ឆេទនៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ និងកាលបរិច្ឆេទផុតកំណត់

ឃ- ឈ្មោះ និង អាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច

ង- ឈ្មោះ និង អាសយដ្ឋានរបស់ភ្នាក់ងារតំណាង (ប្រសិនមាន)

ច- ទំនិញ ឬសេវា ដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានការបញ្ជាក់អំពីចំណាត់ថ្នាក់ នៃទំនិញ ឬសេវាស្របតាមចំណាត់ថ្នាក់អន្តរជាតិ ។

## ផ្នែកទី ២

## ម៉ាកសមូហភាព និងមោឃភាពនៃការចុះបញ្ជី

### មាត្រា ២៣. – ម៉ាកសមូហភាព

មាត្រា៩ រហូតដល់មាត្រា២២ នៃអនុក្រឹត្យនេះ ត្រូវយកមកអនុវត្តចំពោះម៉ាកសមូហភាព តាមលក្ខខណ្ឌតម្រូវមួយចំនួនដូចខាងក្រោម ៖

១-ការទទួលយកពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាព លុះត្រាតែនៅក្នុងពាក្យស្នើសុំចុះបញ្ជីនោះត្រូវកំណត់ថា ជាម៉ាកសមូហភាព និងមានភ្ជាប់មកជាមួយ នូវច្បាប់ចម្លងនៃបទបញ្ជារួមគ្រប់គ្រងការប្រើប្រាស់ម៉ាកនោះមួយច្បាប់ ដោយមានការបញ្ជាក់ត្រឹមត្រូវ ពីអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ។ ការបញ្ជាក់ ដែលធ្វើឡើង ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នោះពុំចាំបាច់តម្រូវឱ្យមានការធ្វើនីត្យានុកូលកម្ម ណាមួយឡើយ ។

២-បទបញ្ជារួមស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ត្រូវកំណត់នូវលក្ខណៈរួម ឬគុណភាពរបស់ទំនិញ ឬសេវាដែលម៉ាកសមូហភាពនោះ ត្រូវជ្រើសរើសយកទៅប្រើប្រាស់ ព្រមទាំង

លក្ខខណ្ឌទាំងឡាយ ដែលបុគ្គលប្រើប្រាស់ម៉ាកសមូហភាពនោះ ត្រូវធ្វើតាម ។ បទបញ្ជានោះ ត្រូវផ្តល់នូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ចំពោះការប្រើប្រាស់ម៉ាកសមូហភាព ដោយស្របទៅតាមប្រការនានានៃបទបញ្ជានោះ ហើយត្រូវកំណត់នូវទណ្ឌកម្មសមល្មម ចំពោះរាល់ការប្រើប្រាស់ដែលផ្ទុយទៅនឹងបទបញ្ជានោះ ។

៣-ច្បាប់ចម្លងមួយច្បាប់ នៃបទបញ្ជារួមស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ត្រូវភ្ជាប់បន្ថែមមកជាមួយនឹងការចុះបញ្ជីម៉ាកសមូហភាពមួយ ។

៤-ការបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកសមូហភាព តាមមាត្រា១៩ (១) នៃអនុក្រឹត្យនេះ ត្រូវរួមបញ្ចូលសេចក្តីសង្ខេបនៃបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ដែលបានភ្ជាប់បន្ថែមទៅនឹងការចុះបញ្ជីម៉ាកសមូហភាព ។

៥-សេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរព័ត៌មាននានា ដែលប៉ះពាល់ដល់បទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

៦-គ្រប់សេចក្តីជូនដំណឹង អំពីការផ្លាស់ប្តូរព័ត៌មានបែបនេះ ចាំបាច់ត្រូវកត់ត្រានៅក្នុងបញ្ជីម៉ាក ។ រាល់ការផ្លាស់ប្តូរព័ត៌មានទាំងឡាយណា នៅក្នុងបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាក នឹងពុំមានប្រសិទ្ធភាពជាធរមានទេ រហូតទាល់តែការកត់ត្រានេះត្រូវបានធ្វើឡើង ។ សេចក្តីសង្ខេបអំពីការផ្លាស់ប្តូរព័ត៌មាន ដែលបានកត់ត្រារួច ចាំបាច់ត្រូវបោះពុម្ពផ្សាយជាសាធារណៈ ។

៧-ក្នុងគោលបំណងនៃការប្រើប្រាស់ម៉ាកសមូហភាព ដែលទាក់ទងនឹងមាត្រា១៥ និង មាត្រា១៦ នៃច្បាប់ ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជីរួច អាចប្រើប្រាស់ម៉ាកសមូហភាពនោះ ដោយខ្លួនឯងបាន លុះត្រាតែម៉ាកនោះ ត្រូវបានប្រើប្រាស់ផងដែរដោយបុគ្គលដទៃទៀត ដែលបានទទួលសិទ្ធិតាមបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកនេះ។ ការប្រើប្រាស់ម៉ាកសមូហភាព ដោយបុគ្គលទាំងនោះ ត្រូវបានចាត់ទុកថា ម៉ាកនោះបានប្រើប្រាស់ ដោយម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ។

## មាត្រា ២៤. – មោឃភាព និង ការលុបម៉ាកចេញពីបញ្ជីដោយផ្អែកលើការមិនបានប្រើប្រាស់

១-អនុលោមតាមមាត្រា១០ (គ) មាត្រា១៣ និង មាត្រា១៥ នៃច្បាប់ ភាគីដែលមានផលប្រយោជន៍ មានសិទ្ធិដាក់ពាក្យស្នើសុំមោឃភាព ចំពោះការចុះបញ្ជីម៉ាក ទោះផុតកំណត់រយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីការបោះពុម្ពផ្សាយ ក្នុងព្រឹត្តិបត្រផ្លូវការក៏ដោយ ។

២-អនុលោមតាមមាត្រា១៣ (ខ) នៃច្បាប់ មន្ត្រីកាន់កាប់បញ្ជី មានសិទ្ធិលុបម៉ាកចេញពីបញ្ជី នៅពេលម្ចាស់ម៉ាកដែលបានចុះបញ្ជី មិនបានបំពេញតាមលក្ខខណ្ឌណាមួយ នៃមាត្រា២ ចំណុច "ក" និង មាត្រា៤ នៃច្បាប់ ។

៣-អនុលោមតាមមាត្រា១៤ (ង) មាត្រា២២ មាត្រា២៣ និង មាត្រា២៨ នៃច្បាប់ ម៉ាកមួយ ត្រូវបានលុបចេញពីបញ្ជី នៅពេលម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិបានប្រើប្រាស់ម៉ាកនោះ ខុសទម្រង់ដើម ដែលបានចុះបញ្ជី ហើយរំលោភបំពានទៅលើម៉ាករបស់អ្នកផ្សេង ដែលបានចុះបញ្ជីរួច ។

៤-អនុលោមតាមមាត្រា៤ (ង) មាត្រា១៤ (ង) មាត្រា២២ មាត្រា២៣ និង មាត្រា២៨ នៃច្បាប់ ម៉ាកមួយ ត្រូវបានលុបចេញពីបញ្ជីនៅពេលម្ចាស់ម៉ាកនោះ ឬអ្នកទទួលសិទ្ធិបានបន្ថែមស្លាកសញ្ញា ដូច ឬស្រដៀង ធ្វើឱ្យភន្តច្រឡំ ទៅនឹងស្លាកសញ្ញាល្បីរបស់អ្នកផ្សេង ដែលបានប្រើប្រាស់មុន ។

៥-ការលុបម៉ាកមួយចេញពីបញ្ជី ចាំបាច់ត្រូវតែបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

៦-មានតែការលុបម៉ាកចេញពីបញ្ជី ដោយផ្អែកលើមូលហេតុមិនបានប្រកាស អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកតែម្យ៉ាងគត់ ដែលត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីឡើងវិញ តាមការស្នើសុំរបស់ ម្ចាស់ម៉ាក ឬភ្នាក់ងារតំណាងក្នុងរយៈពេលមិនលើសពី ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃសម្រេចលុប ។

៧-ក្រោយពីមានសេចក្តីសម្រេច របស់មន្ត្រីកាន់កាប់បញ្ជី អំពីការផ្តល់មោឃភាពនៃការចុះបញ្ជី ឬ រក្សាទុកការចុះបញ្ជី ឬមួយសម្រេចឱ្យកែតម្រូវម៉ាកដែលបានចុះបញ្ជី បើភាគីណាមួយមិនយល់ព្រមនឹង សេចក្តីសម្រេចនោះ អាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា របស់ក្រសួងពាណិជ្ជកម្ម ឬប្តឹងទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេច ។

៨-អនុលោមតាមមាត្រា៦២ នៃច្បាប់ ភាគីមានផលប្រយោជន៍ មានសិទ្ធិប្តឹងតវ៉ា អំពីសេចក្តី សម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា របស់ក្រសួងពាណិជ្ជកម្ម ទៅតុលាការមានសមត្ថកិច្ច ក្នុង រយៈពេល ០៣ (បី)ខែ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេច ។

៩-ការបង្កើតក្រុមប្រឹក្សាប្តឹងតវ៉ា សមាសភាព និង ដែនអំណាចនៃក្រុមប្រឹក្សាប្តឹងតវ៉ា និង នីតិវិធីដោះស្រាយទំនាស់នឹងត្រូវកំណត់ ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

១០-អនុលោមតាមមាត្រា៦២ នៃច្បាប់ នៅពេលតុលាការសម្រេចលើបណ្តឹងតវ៉ា តម្រូវឱ្យ លុបម៉ាកចេញពីបញ្ជី ឬរក្សាទុក ឬកែតម្រូវម៉ាក មន្ត្រីកាន់កាប់បញ្ជី ត្រូវអនុវត្តតាមសេចក្តីសម្រេចនោះ ។

## ផ្នែកទី ៣

## ការកំណត់បែបបទរដ្ឋបាលសម្រួលដល់ការចុះបញ្ជី និងការដោះស្រាយ វិវាទ ព្រមទាំងការផ្ទេរសិទ្ធិ

### មាត្រា ២៥. – អាសយដ្ឋានសម្រាប់ទាក់ទង

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ចាំបាច់ត្រូវផ្តល់មកឱ្យមន្ត្រីកាន់កាប់បញ្ជី នូវអាសយដ្ឋានសម្រាប់ ទាក់ទងនៅក្នុងប្រទេសកម្ពុជា ដែលប្រើប្រាស់ក្នុងគោលបំណងនៃការដាក់ពាក្យ ។

ជនទាំងឡាយណា ដែលពាក់ពន្ធ័នឹងកិច្ចការនានាទាក់ទងនឹងម៉ាក ត្រូវផ្ដល់អាសយដ្ឋានទាក់ទងក្នុងប្រទេសកម្ពុជាដល់មន្ត្រីកាន់កាប់បញ្ជី ។

## មាត្រា ២៦. – ការផ្លាស់ប្ដូរឈ្មោះ អាសយដ្ឋាន ឬ អាសយដ្ឋានសម្រាប់ទាក់ទង

១-ការស្នើសុំប្ដូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬអាសយដ្ឋានសម្រាប់ទាក់ទង ចំពោះពាក្យស្នើសុំចុះបញ្ជីម៉ាក ឬម៉ាកដែលបានចុះបញ្ជីរួច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវទូទាត់កម្រៃដូចមានចែងក្នុងប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-មុនពេលអនុវត្តតាមសំណើនៃការសុំប្ដូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬ អាសយដ្ឋាន ទាក់ទងមន្ត្រីកាន់កាប់បញ្ជីត្រូវទាមទាររកភស្តុតាងនៃការសុំប្ដូរនោះ ។

៣-ប្រសិនបើសំណើសុំប្ដូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬអាសយដ្ឋានសម្រាប់ទាក់ទង ត្រូវបានអនុញ្ញាត មន្ត្រីកាន់កាប់បញ្ជី ត្រូវធ្វើការកែតម្រូវ ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬកត់ត្រាក្នុងបញ្ជីដើមនៃម៉ាក និង កត់ត្រាក្នុងបញ្ជីម៉ាក ។

## មាត្រា ២៧. – ការប្ដូរម្ចាស់កម្មសិទ្ធិ កិច្ចសន្យាផ្ដល់អាជ្ញាប័ណ្ណ

១-សំណើសុំប្ដូរម្ចាស់កម្មសិទ្ធិ ដែលអនុញ្ញាតដោយច្បាប់តាមមាត្រា៤៨ ត្រូវធ្វើឡើងតាមគំរូដែលមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម រួចផ្ញើជូនមកមន្ត្រីកាន់កាប់បញ្ជី ដោយត្រូវទូទាត់កម្រៃ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-ការបោះពុម្ពផ្សាយជាសាធារណៈ អំពីការប្ដូរម្ចាស់កម្មសិទ្ធិ ត្រូវបញ្ជាក់នូវព័ត៌មានដូចតទៅ ៖

ក- ម៉ាក ដែលពាក់ព័ន្ធនឹងការប្ដូរម្ចាស់កម្មសិទ្ធិនេះ

ខ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

គ- កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក កាលបរិច្ឆេទទាមទារសិទ្ធិអាទិភាព ( ប្រសិនបើមាន) និងកាលបរិច្ឆេទនៃការចុះបញ្ជីម៉ាក

ឃ- ឈ្មោះ អាសយដ្ឋានម្ចាស់ម៉ាកដើម និង ឈ្មោះ អាសយដ្ឋានម្ចាស់ម៉ាកថ្មីដែលពាក់ព័ន្ធ នឹងការប្ដូរម្ចាស់កម្មសិទ្ធិនេះ

ង- ថ្ងៃ ខែ ឆ្នាំ ប្ដូរឈ្មោះម្ចាស់កម្មសិទ្ធិ ។

៣-កិច្ចសន្យាផ្ដល់អាជ្ញាប័ណ្ណ ដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ដើម្បីស្នើសុំធ្វើការកត់ត្រាតាមមាត្រា៥២ នៃច្បាប់ ត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រថតចម្លងមួយច្បាប់ និងលិខិតប្រគល់សិទ្ធិ និងកិច្ចសន្យាផ្ដល់អាជ្ញាប័ណ្ណច្បាប់ដើម ឬច្បាប់ចម្លង ដែលបញ្ជាក់ភាពត្រឹមត្រូវមួយច្បាប់ ។

## មាត្រា ២៨. – ការចាត់តាំងភ្នាក់ងារតំណាង អាសយដ្ឋានសម្រាប់ទាក់ទង

ការចាត់តាំងភ្នាក់ងារតំណាងមួយ ត្រូវធ្វើឡើងដោយមានលិខិតប្រគល់សិទ្ធិ ដែលត្រូវបញ្ជាក់ភាពស្របច្បាប់ និងចុះហត្ថលេខា ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកច្រើននាក់ ការចុះហត្ថលេខាត្រូវធ្វើឡើង ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកទាំងនោះ ។ អាសយដ្ឋានរបស់ភ្នាក់ងារតំណាង ត្រូវបានចាត់ទុកថាជាអាសយដ្ឋានប្រើប្រាស់សម្រាប់ទាក់ទងរវាងបុគ្គលម្នាក់ ឬ ច្រើននាក់ដែលត្រូវបានចាត់តាំងជាភ្នាក់ងារតំណាង ហើយព័ត៌មានផ្សេងៗត្រូវផ្ញើតាមរយៈភ្នាក់ងារតំណាងនោះ ។

## មាត្រា ២៩. – ចំនួនថ្ងៃដែលពុំត្រូវរាប់បញ្ចូល

នៅពេលដែលថ្ងៃចុងក្រោយសម្រាប់បំពេញការងារ ឬសម្រាប់ចាត់វិធានការណាមួយ ត្រូវចំថ្ងៃឈប់សម្រាក ថ្ងៃបន្ទាប់ត្រូវបានចាត់ទុកថា ស្របច្បាប់ ចំពោះការបំពេញការងារ ឬ ចាត់វិធានការ ។

## មាត្រា ៣០. – ការស្នើសុំពិនិត្យបញ្ជីម៉ាក និងការស្នើសុំដកស្រង់ព័ត៌មានពីបញ្ជីម៉ាក

ការស្នើសុំពិគ្រោះយោបល់អំពីបញ្ជីម៉ាក ត្រូវបានអនុញ្ញាត ដោយផ្អែកតាមសំណើជាលាយលក្ខណ៍អក្សរ របស់ភាគីណាមួយដែលមានផលប្រយោជន៍ មន្ត្រីកាន់កាប់បញ្ជី ត្រូវធ្វើការថតចម្លងឯកសារក្នុងបញ្ជីម៉ាក និងឯកសារដទៃទៀត ព្រមទាំងបញ្ជាក់ភាពត្រឹមត្រូវផង ។

## មាត្រា ៣១. – ការកែតម្រូវកំហុស

ការកែតម្រូវកំហុសតាមមាត្រាទី៥៦ នៃច្បាប់ អាចធ្វើឡើងដោយមន្ត្រីកាន់កាប់បញ្ជី នៅពេលបានទទួលសំណើជាលាយលក្ខណ៍អក្សរ ហើយដែលសំណើនោះបានបំពេញតាមលក្ខខណ្ឌទាំងឡាយ ដែលមន្ត្រីកាន់កាប់បញ្ជីយល់ថា សមស្រប ឬ ធ្វើឡើងតាមគំនិតផ្តួចផ្តើមផ្ទាល់របស់មន្ត្រីកាន់កាប់បញ្ជី ។ រាល់ការកែតម្រូវ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅបុគ្គលទាំងអស់ដែលមានការពាក់ព័ន្ធ ហើយត្រូវបោះពុម្ពផ្សាយជាសាធារណៈ ដោយមន្ត្រីកាន់កាប់បញ្ជី បើយល់ឃើញថា ជាការចាំបាច់ ។

## មាត្រា ៣២. – សវនាការ

១-មន្ត្រីកាន់កាប់បញ្ជី ត្រូវចាត់ចែងឱ្យមានសវនាការ បើភាគីណាមួយ ឬភាគីទាំងពីរនៃជំលោះស្នើសុំជាលាយលក្ខណ៍អក្សរ ឱ្យមានសវនាការមុនពេលចេញសេចក្តីសម្រេចណាមួយ ។ ពាក្យស្នើសុំសវនាការនេះ ត្រូវធ្វើឡើងនៅមុនពេល ឬក្រោយពេល ០១ (មួយ) ខែ នៃថ្ងៃដាក់ពាក្យបណ្តឹង ឬឯកសារគាំទ្ររបស់ខ្លួនមកមន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណីគ្មានពាក្យស្នើសុំសវនាការ ជាផ្លូវការតាមការកំណត់ខាងលើ តាមឆន្ទានុសិទ្ធិដែលផ្តល់ដោយច្បាប់ ឬដោយអនុក្រឹត្យនេះ មន្ត្រីកាន់កាប់បញ្ជីអាច

ចេញសេចក្ដីសម្រេចរបស់ខ្លួន ដោយគ្មានសវនាការ ឬបើយល់ថា ចាំបាច់ត្រូវអញ្ជើញភាគីនៃជម្លោះមកធ្វើសវនាការ ។

២-នៅពេលទទួលបានសំណើសុំធ្វើសវនាការ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទ នៃការបើកសវនាការយ៉ាងតិច ០៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការមុនពេលបើកសវនាការ ទៅឱ្យបុគ្គលដែលបានដាក់ពាក្យស្នើសុំធ្វើសវនាការ និងបុគ្គលដែលពាក់ព័ន្ធដទៃទៀត ។

## មាត្រា ៣៣. – ទំនាក់ទំនងតាមរយៈប្រៃសណីយ៍

១-សេចក្ដីជូនដំណឹង ពាក្យស្នើសុំ ឬឯកសារដទៃទៀត ដែលផ្ញើទៅឱ្យមន្ត្រីកាន់កាប់បញ្ជី តាមបញ្ញើប្រៃសណីយ៍ ត្រូវបានចាត់ទុកថា បានផ្ដល់នៅត្រឹមកាលបរិច្ឆេទ ដែលបញ្ញើទាំងនោះត្រូវបានទទួលដោយការិយាល័យមន្ត្រីកាន់កាប់បញ្ជី។ នៅពេលទទួលបានឯកសារទាំងនោះ ការិយាល័យមន្ត្រីកាន់កាប់បញ្ជី ត្រូវវាយត្រាចូល ចុះលេខ ថ្ងៃ ខែ ឆ្នាំទទួលជាបន្ទាន់ ដើម្បីជាភស្តុតាងបញ្ជាក់ អំពីពេលវេលាទទួលឯកសារទាំងនោះ ។

២-កថាខ័ណ្ឌ ១ ខាងលើ នឹងមិនត្រូវបានអនុវត្តទេ ចំពោះការកំណត់អំពីកាលបរិច្ឆេទដាក់ពាក្យក្នុងករណីផ្ទុយនឹងមាត្រា១៦ នៃអនុក្រឹត្យនេះ។

## មាត្រា ៣៤. – ភស្តុតាង

១-ភស្តុតាងទាំងឡាយដែលដាក់ជូនពិនិត្យ ត្រូវធ្វើឡើងតាមរយៈលិខិតប្រកាស ឬតាមរយៈលិខិតថ្លែងសច្ចា។

២-ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីយល់ថា សមស្របចំពោះករណីដោយឡែកណាមួយ មន្ត្រីកាន់កាប់បញ្ជី អាចសាកសួរដោយផ្ទាល់មាត់ជាជំនួស ឬជាការបន្ថែមលើភស្តុតាងដទៃទៀត ហើយអនុញ្ញាតឱ្យសាក្សីណាមួយចូលរួម ដើម្បីបញ្ជាក់លើលិខិតថ្លែងសច្ចា ឬលិខិតប្រកាសរបស់ខ្លួន ។

## មាត្រា ៣៥. – លិខិតប្រកាស និងលិខិតថ្លែងសច្ចា

លិខិតប្រកាស ឬលិខិតថ្លែងសច្ចា ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីកុងស៊ុល ឬសារការី ឬអ្នកប្រកបវិជ្ជាជីវៈច្បាប់ ដែលមានការទទួលស្គាល់ត្រឹមត្រូវ ។

## មាត្រា ៣៦. – អាជ្ញាធរមានសមត្ថកិច្ច

អាជ្ញាធរមានសមត្ថកិច្ច ដែលមានចែងក្នុងមាត្រា៣៥ មាត្រា៣៧ មាត្រា៣៨ មាត្រា៤២ និងមាត្រា៤៦ នៃច្បាប់ រួមមានអង្គភាពគយ និងរដ្ឋាករ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនិងបរិវាណ-

អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ ហៅកាត់ថាកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម និង នគរបាលមានសមត្ថកិច្ចនៃក្រសួងមហាផ្ទៃ ។

**មាត្រា ៣៧. – ការបោះពុម្ពផ្សាយ និង ព្រឹត្តិបត្រផ្លូវការ**

ចំណុចពិសេសទាំងឡាយរបស់ម៉ាក និងចំណាត់ការនានា ព្រមទាំងព័ត៌មានផ្សេងទៀត ដែលតម្រូវឱ្យបោះពុម្ពផ្សាយដោយច្បាប់ ឬអនុក្រឹត្យនេះ ត្រូវតែបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ តាមការណែនាំរបស់មន្ត្រីកាន់កាប់បញ្ជី ។

## ជំពូកទី ៤

## វិធានការតាមមាត់ច្រកព្រំដែន

**មាត្រា ៣៨. – ពាក្យប្ដឹង**

១-អនុលោមតាមមាត្រា៣៥ និងមាត្រា៣៦ នៃច្បាប់ និង ច្បាប់ ស្ដីពីកាគ្រប់គ្រង គុណភាពសុវត្ថិភាពលើផលិតផលទំនិញ និងសេវា ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬអ្នកទទួលអាជ្ញាប័ណ្ណ ឬភ្នាក់ងារតំណាងស្របច្បាប់ អាចធ្វើពាក្យប្ដឹងទៅរដ្ឋបាលគយ និង រដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការឱ្យព្យួរទុកនូវការធ្វើបែបបទទំនិញណា ដែលសង្ស័យថា មានម៉ាកក្លែងក្លាយ ដោយបង្ហាញនូវភស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី ។

២-ក្នុងរង្វង់មិនលើសពី ៣០ (សាមសិប ) ថ្ងៃ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ត្រូវចេញប្រកាសអន្តរក្រសួងមួយ អំពីគំរូនៃពាក្យប្ដឹង និងតម្រូវការនានាស្របតាមច្បាប់ជាធរមាន ។

៣-ពាក្យប្ដឹងនោះមានសុពលភាព ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យប្ដឹង ។ ពេលផុតសុពលភាព អ្នកដាក់ពាក្យត្រូវធ្វើពាក្យប្ដឹងឡើងវិញ បើសំណូមពរនៃការឃាត់ និងត្រួតពិនិត្យទំនិញនៅមាននៅឡើយ ។

**មាត្រា ៣៩. – កម្រៃរដ្ឋបាល**

ពាក្យប្ដឹងនីមួយៗ ត្រូវអមមកជាមួយនូវការទូទាត់កម្រៃរដ្ឋបាល ដែលកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៤០. – កាតព្វកិច្ចរបស់អ្នកដាក់ពាក្យប្ដឹង**

ក្រៅពីកាតព្វកិច្ចនានាដែលមានចែងក្នុងមាត្រា៣៥ មាត្រា៣៦ និងមាត្រា៣៨ នៃច្បាប់ អ្នកដាក់ពាក្យមានភារកិច្ចទទួលខុសត្រូវ ចំពោះមធ្យោបាយដឹកជញ្ជូន ឃ្លាំងដែលត្រូវស្តុកទំនិញនៅពេល

ឃាត់រក្សាទុក។ ឃ្លាំងស្តុកទំនិញត្រូវស្ថិតនៅក្នុងបរិវេណកំពង់ផែ ឬក្នុងបរិវេណមាត់ច្រកនាំចេញ នាំចូល ដែលបានកំណត់ និងគ្រប់គ្រងដោយអាជ្ញាធរមានសមត្ថកិច្ច តាមច្បាប់ជាធរមាន។ ការចំណាយនានាក្នុង ការបំផ្លាញចោលទំនិញមិនស្របច្បាប់ ជាកាតព្វកិច្ចរបស់អ្នកដាក់ពាក្យ ។

**មាត្រា ៤១. – ការបដិសេធចំពោះការឃាត់ទុកទំនិញសង្ស័យថា មានម៉ាកក្លែងក្លាយ**

អង្គភាពគយ និងរដ្ឋាករ ឬ កាំកុងត្រូល អាចមានសិទ្ធិបដិសេធការស្នើសុំឃាត់ទំនិញ ដែលសង្ស័យ ឬមានម៉ាកក្លែងក្លាយ តែក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំឃាត់ទំនិញ មិនបានអនុវត្តតាម ការទាមទារណាមួយ របស់អង្គភាពគយ និងរដ្ឋាករ ឬ កាំកុងត្រូល ដែលស្របតាមមាត្រានានានៃច្បាប់ និងអនុក្រឹត្យនេះប៉ុណ្ណោះ។

**មាត្រា ៤២. – ចំណាត់ការ និង ថេរៈវេលា**

បែបបទ និងថេរៈវេលានៃចំណាត់ការនានារបស់អង្គភាពគយ និងរដ្ឋាករ និង ឬកាំកុងត្រូល ត្រូវអនុលោមតាមជំពូកទី១០ នៃច្បាប់ និង មាត្រានានានៃអនុក្រឹត្យនេះ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ៤៣. –**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤៤. –**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមាន ប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

ភ្នំពេញ, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ